**សម្រេច**

**ប្រការ ១ :** អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យព្រែកអំបិលបច្ចុប្បន្នទៅជា«អនុវិទ្យាល័យ **ហ៊ុន សែន**– ព្រែកអំបិល » ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

**ប្រការ២** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា–ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកណ្តាល និង នាយកអនុវិទ្យាល័យ ហ៊ុន សែន– ព្រែកអំបិល មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
**គា សាវាន**

* * *

ភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

**ប្រកាសលេខ: ៣២៨ អយក.ប្រក**

**ស្តីពីការបើក អនុវិទ្យាល័យ ហ៊ុន សែន–ត្រប់ ក្នុងស្រុកបាធាយ**

**ខេត្ត កំពង់ចាម**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។
- បានឃើញក្រឹត្យ–ច្បាប់លេខ៣០ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃ ០២ ខែ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត ១ –កំរិត ២
- យោងលិខិតលេខ ២១៦ អយក.បផ ចុះថ្ងៃទី ២០ កក្កដា ១៩៩៥ របស់ប្រធានការិយាល័យអប់រំ យុវជន និង កីឡាស្រុកបាធាយ ដោយមានការឯកភាពពីប្រធានមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពង់ចាម
- តាមសំណើររបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡាខេត្តកំពង់ចាមបើក អនុវិទ្យាល័យ ដែលមាន ឈ្មោះថា" អនុវិទ្យាល័យ **ហ៊ុន សែន – ត្រប់**" នៅក្នុងស្រុកបាធាយខេត្តកំពង់ចាម ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ នេះតទៅ ។

**ប្រការ ២** : អនុវិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមចាំបាច់ព្រមទាំងបុគ្គលិក ផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣** :នាយក–នាយករងនៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់ នាយក-នាយករង នៃអនុវិទ្យាល័យ ។

**ប្រការ ៤** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជននិងកីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តកំពង់ចាម នាយកអនុវិទ្យាល័យ **ហ៊ុន សែន** ត្រប់ មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
**គា សាឃាន**